# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១១

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 03 / 02 / 2011
ម៉ោង (Time/Heure): 13:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ: សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើជាបន្ទាន់សុំចាត់តាំងអ្នកជំនាញផ្នែកសម្បទា

---

ដាក់ដោយ៖

**សហមេធាវីការពារក្តីលោក នួន ជា**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

លោក Andrew IANUZZI

លោក Jasper PAUW

លោក ព្រំ ផល្លា

លោក Göran SLUITER

លោក Annebrecht VOSSENBERG, Xinyi LIM និង

Vincent VLEUGEL (កម្មសិក្សាការីច្បាប់)

ផ្ញើជូន៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមសហមេធាវីការពារក្តីទាំងអស់**

## I. សេចក្តីផ្តើម

១. អនុលោមតាមវិធាន៣២ នៃវិធានផ្ទៃក្នុងរបស់ អវតក ("វិធាន") សហមេធាវីការពារក្តីជនជាប់ចោទ **នួន ជា** ("មេធាវីការពារក្តី") សូមដាក់សំណើនេះទៅអង្គជំនុំជម្រះសាលាដំបូង សុំចេញដីកាចាត់តាំងអ្នកជំនាញមួយដែលមានលក្ខណៈសម្បត្តិពេញលេញ ដើម្បីសម្រេចថាតើលោក **នួន ជា** មានសម្បទាទាំងផ្នែករាងកាយ និងផ្លូវចិត្តគ្រប់គ្រាន់ ដើម្បីចូលរួមក្នុងការជំនុំជម្រះក្តីបានដែរឬអត់នោះ។

២. ចំពោះសំអាងហេតុដូចមានរៀបរាប់ខាងក្រោមនេះ មេធាវីការពារក្តីសូមស្នើថា៖ (i) សំណើសុំនេះអាចទទួលយកបាន (ii) ដោយសារថា សមត្ថភាពរបស់លោក **នួន ជា** ចូលរួមក្នុងការជំនុំជម្រះក្តីមិនមានភាពច្បាស់លាស់ជាសត្យានុម័ត នោះអង្គជំនុំជម្រះសាលាដំបូងគួរចេញដីកាចាត់តាំងឲ្យមានការវាយតម្លៃពីអ្នកជំនាញក្នុងករណីចាំបាច់ (iii) ក្នុងការសម្រេចបែបនេះ អ្នកជំនាញ ("អ្នកជំនាញម្នាក់/ច្រើននាក់ដែលបានស្នើសុំ") គួរទទួលបានការណែនាំជាក់លាក់ ដើម្បីរៀបចំពិនិត្យសម្បទា ដែលអាចឆ្លុះបញ្ចាំងបានយ៉ាងពេញលេញទៅនឹងភាពស្មុគស្មាញនៃកិច្ចដំណើរការនីតិវិធីរបស់ អវតក និងភាពជាក់ស្តែងនៃស្ថានភាពសុខភាពទាំងផ្នែករាងកាយ និងផ្លូវចិត្តរបស់ជនជាប់ចោទ ហើយ (iv) របាយការណ៍អ្នកជំនាញគួរយកទៅប្រើប្រាស់យ៉ាង*មធ្យ័ត* សម្រាប់ជាគោលបំណងនៃការពិចារណាទៅលើសម្បទារបស់លោក **នួន ជា** ដើម្បីចូលរួមក្នុងការជំនុំជម្រះក្តី។ ជាគោលការណ៍ ទោះបីលោក **នួន ជា** នឹងសហការនៅក្នុងកិច្ចដំណើរការនេះក្នុងកម្រិតមួយដែលមិនប៉ះពាល់ដល់បុព្វសិទ្ធិរបស់គាត់ក្នុងការមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនក្តីក៏ដោយ ក៏គាត់នឹងមិនបោះបង់សិទ្ធិក្នុងការបង្ហាញវត្តមានទៅតាមដំណាក់កាលនីមួយៗ ក្នុងការជំនុំជម្រះក្តីលើរូបគាត់ដែលនឹងឈានមកដល់ក្នុងពេលដ៏ខ្លីខាងមុខនេះដែរ។

៣. ដោយសារអង្គហេតុសម្រាប់គាំទ្រដល់សំណើសុំជាបន្ទាន់នេះមានលក្ខណៈផ្ទាល់ខ្លួន និងជាឯកជន មេធាវីការពារក្តីសូមស្នើថា ពាក្យសុំនេះគួរចាត់ថ្នាក់ជាឯកសារសម្ងាត់បំផុត។ ទោះជាយ៉ាងណាក្តីទាក់ទិននឹងបញ្ហាអង្គច្បាប់សំខាន់ៗដែលបានលើកឡើងនៅក្នុងសំណើសុំនេះ និងផលប្រយោជន៍ទូទៅនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការប្រកបដោយតម្លាភាព នោះចំណុចខ្លះនៃសំណើសុំនេះគួរត្រូវបានលុបចោល មុននឹងផ្សព្វផ្សាយជាសាធារណៈ។

## II. ប្រវត្តិនៃនីតិវិធី

៤. នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ មេធាវីការពារក្តីបានដាក់សំណើសុំទៅការិយាល័យសហចៅក្រម

ស៊ើបអង្កេត ("កសចស") ស្នើសុំតែងតាំង "អ្នកជំនាញដើម្បីពិនិត្យសម្បទារបស់លោក **នួន ជា** ដើម្បីចូលរួមក្នុងការជំនុំជម្រះក្តី" ដោយបង្ហាញទឡ្ហីករណ៍ថា "បញ្ហាគឺជាការព្រួយបារម្ភដែលកំពុងតែបន្តមាន ហើយ [...] មិនទាន់ត្រូវបានវាយតម្លៃឲ្យបានច្បាស់លាស់ និងដាច់ស្រេចនៅឡើយទេ"[១]។ សំណើសុំនេះត្រូវបាន កសចស ច្រានចោលតាមទំនើងចិត្ត[២]។ ចំពោះបណ្តឹងឧទ្ធរណ៍លើបញ្ហានេះ អង្គបុរេជំនុំជម្រះ ("អបជ") បានសម្រេចថា "ជាគោលការណ៍ ជនត្រូវចោទទទួលបានសិទ្ធិ [...] [ទទួលបានការកំណត់អំពីសម្បទា] ក្នុងអំឡុងពេលស៊ើបអង្កេត និងដំណាក់កាលមុនអង្គសេចក្តី"[៣] ប៉ុន្តែ សំណើសុំរបស់មេធាវីការពារក្តីពុំមានយុត្តិកម្មតាមអង្គហេតុឡើយ[៤]។

៥. រយៈពេលជិតពីរឆ្នាំ ក្រោយពីមេធាវីការពារក្តីបានដាក់សំណើសុំដំបូងរបស់ខ្លួនមក កសចស បានតែងតាំងគ្រូពេទ្យចិត្តសាស្ត្រពីរនាក់ ("អ្នកជំនាញពីមុន") ដើម្បីវាយតម្លៃថាតើលោក **នួន ជា** មានសម្បទាដើម្បីចូលរួមសវនាការដែរឬយ៉ាងណានោះ[៥]។ មេធាវីការពារក្តីបានប្រាប់ជនជាប់ចោទមិនឲ្យសហការនៅក្នុងការពិនិត្យសុខភាពតាមការស្នើសុំនោះទេ ដោយសារថា នៅក្នុងចំណោមកត្តាជាច្រើន អាណត្តិការងាររបស់អ្នកជំនាញពីមុនមិនមានភាពច្បាស់លាស់អាចអនុញ្ញាតឲ្យបំពេញការងារទៅបាននោះទេ និងបានបង្កឲ្យមានកង្វល់ជាច្រើនថា លទ្ធផលនៃការពិនិត្យសុខភាពនោះអាចនឹងត្រូវបានយកទៅប្រើប្រាស់ដោយមិនត្រឹមត្រូវ[៦]។ កសចស បានបន្តណែនាំដល់អ្នកជំនាញពី

---

[១] ឯកសារលេខ D-54 "ពាក្យសុំតែងតាំងអ្នកជំនាញ" ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ ERN 00156972–00156988 កថាខណ្ឌ១។

[២] ឯកសារលេខ D-54/IV លិខិតរបស់ កសចស ផ្ញើជូនលោក សុន អរុណ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៨ ERN 00171400។

[៣] ឯកសារលេខ D-54-V-5, អបជ៖ "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ទាក់ទងនឹងការចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៨ ERN 00233587–00233598 (សាលដីកាស្តីពីសម្បទារបស់ នួន ជា) កថាខណ្ឌ២៧ (ក្នុងករណីនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បញ្ហាសម្បទា ពិតជាកើតមាននៅក្នុងដំណាក់កាលនេះ ដែលវាផ្ទុយពីការអះអាងរបស់សហចៅក្រមស៊ើបអង្កេត)។

[៤] សាលដីកាស្តីពីសម្បទារបស់ នួន ជា កថាខណ្ឌ២៨-៤៣។

[៥] ឯកសារលេខ B-35 "ដីកាសម្រេចចាត់តាំងអ្នកជំនាញ" ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ERN 00379010–00379013។

[៦] ឯកសារលេខ B-35/2 លិខិតរបស់មេធាវីការពារក្តី ផ្ញើជូន កសចស ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៩ ERN 00389599–00389603។ *កំណត់សម្គាល់ពិសេស៖* មេធាវីការពារក្តីបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងលិខិតរបស់ខ្លួនថា "មិនត្រូវបានបកស្រាយថា ច្រានចោលការលើកឡើងដោយមេធាវីការពារក្តីថា [នួន ជា] មិនអាចប្រឈមនឹងការជំនុំជម្រះ ឬក៏ច្រានចោលសំណើឲ្យមានកោសល្យវិច័យចិត្តសាស្ត្រនោះឡើយ"។ *ដូចជើងទំព័រខាងលើ*។

មុន[៧] ប៉ុន្តែ ការប៉ុនប៉ងជួបជាមួយលោក **នួន ជា** មិនបានជោគជ័យឡើយ ហើយនៅទីបំផុត ពួកគេមិនអាចបំពេញការងារតាមការចាត់តាំងបានឡើយ[៨]។ ទោះបីអ្នកជំនាញពីមុនបានកត់សម្គាល់ថា "ការពិនិត្យឡើងវិញទៅលើឯកសារពេទ្យរបស់ [នួន ជា] មិនបង្ហាញពីប្រវត្តិនៃបញ្ហាផ្លូវចិត្តពីអតីតកាល"[៩] ក៏ដោយ ក៏អ្នកជំនាញបានសន្និដ្ឋានថា "ទោះបីជាយ៉ាងណាក៏ដោយ មតិយោបល់ពាក់ព័ន្ធនឹងបញ្ហាផ្លូវចិត្ត ឬសម្បទាដើម្បីចូលរួមក្នុងការជំនុំជម្រះក្តីនៅដំណាក់កាលនេះ គឺជាការយល់ឃើញ"បណ្តោះអាសន្ន"តែប៉ុណ្ណោះ និង*ត្រូវការធ្វើការវាយតម្លៃជាថ្មីឡើងវិញ នៅពេលណាដែលកិច្ចដំណើរការនីតិវិធីជំនុំជម្រះត្រូវបានធ្វើឡើង*"[១០]។

៦. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១[១១]។

## III. អង្គហេតុពាក់ព័ន្ធ

៧. [redacted]។

---

[៧] *សូមមើល* ឯកសារលេខ B-35/4 លិខិតរបស់ កសចស ផ្ញើជូនអ្នកជំនាញ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ ERN 00391846។

[៨] *សូមមើល* ឯកសារលេខ B-35/6.2 លិខិតរបស់អ្នកជំនាញ ផ្ញើជូន កសចស ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩ ERN 00392356។ ឯកសារលេខ B-35/7 "របាយការណ៍កោសល្យវិច័យផ្នែកចិត្តសាស្ត្រ" ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៩ ERN 00407300–00407305 (របាយការណ៍អ្នកជំនាញលើកមុន) ទំព័រ៥។

[៩] របាយការណ៍អ្នកជំនាញលើកមុន ទំព័រ៦។ *សូមមើលផងដែរ* ឯកសារលេខ D-427 "ដីកាដំណោះស្រាយ" ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ERN 00604508–00605246 កថាខណ្ឌ ១៥៨៤ (ដែលចៅក្រមស៊ើបអង្កេតបានធ្វើការកត់សម្គាល់ទៅលើចំណុចនេះ)។

[១០] របាយការណ៍អ្នកជំនាញលើកមុន ទំព័រ៦ (គូសបញ្ជាក់បន្ថែម)។

[១១] *សូមមើល* ឯកសារលេខ E-9 "ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ" ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ ERN 00635754-00635759។ កថាខណ្ឌ ២ ("[...] ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ គឺជាកាលបរិច្ឆេទដែលក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿងពីអង្គបុរេជំនុំជម្រះ")។

[១២] [redacted]

00641441



៨. [redacted]៖

ក. [redacted]

ខ. [redacted]

គ. [redacted]

---

១៣ [redacted]

១៤

១៥

១៦

១៧

១៨

00641442



ឃ. [redacted]

ង. [redacted]

ច. [redacted]

ឆ. [redacted]

ជ. [redacted]

---

១៩ [redacted]

២០ [redacted]

២១ [redacted]

២២ [redacted]

00641443



[redacted]

ឈ. [redacted]

ញ. [redacted]

---

២៣ [redacted]

២៤ [redacted]

២៥ [redacted]

ង. ក្នុងសវនាការសាធារណៈនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ ជនជាប់ចោទត្រូវបានអនុញ្ញាតឲ្យចាកចេញពីសវនាការដោយមូលហេតុដូចគ្នា។

[redacted]

## IV. អង្គច្បាប់ដែលពាក់ព័ន្ធ

### ក. សម្បទា ចូលរួមក្នុងការជំនុំជម្រះក្តី

### *១. ការតែងតាំងអ្នកជំនាញ*

៩. វិធានចែងយ៉ាងច្បាស់ពីការសម្រេចរបស់អ្នកជំនាញទៅលើសម្បទារបស់ជនជាប់ចោទ ដើម្បីចូលរួមក្នុងការជំនុំជម្រះ។ ដោយឡែក វិធាន៣២ បានចែងដូចខាងក្រោម៖

> ក្នុងគោលបំណងដើម្បីបញ្ជាក់ថា ជនត្រូវចោទ ឬជនជាប់ចោទមានសម្បទាខាងផ្លូវកាយ និងផ្លូវចិត្តអាច ចូលរួមក្នុងការជម្រះក្តី ឬក៏ដោយសារមូលហេតុផ្សេងទៀត ឬតាមសំណើរបស់ភាគីណាមួយ [...] ឬអង្គជំនុំជម្រះអាចបង្គាប់ឲ្យជនត្រូវចោទ ឬជនជាប់ចោទទទួលការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រវិកលចរិក ឬ ចិត្តសាស្ត្រដោយអ្នកជំនាញ។មូលហេតុនៃការចេញសេចក្តីបង្គាប់បែបនេះ និងរបាយការណ៍របស់អ្នកជំនាញ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។

ការពិនិត្យសម្បទាអាចត្រូវបានបង្គាប់ឲ្យធ្វើឡើង នៅតាមដំណាក់កាលនានានៃកិច្ចដំណើរការ

[redacted]

នីតិវិធី ដោយមិនគិតទៅដល់ករណីថាតើ ធ្លាប់មានការវាយតម្លៃពីមុនមកឬយ៉ាងណានោះទេ[២៦]។ វិធានផ្ទៃក្នុងបានចែងយ៉ាងច្បាស់ពីការវាយតម្លៃទៅលើបញ្ហានេះ នៅមុនពេលសវនាការ។ អនុលោមតាមវិធាន៧៩(៧) គោលបំណងមួយដោយឡែក ក្នុងចំណោមគោលបំណងនានានៃកិច្ចប្រជុំត្រៀមរៀបចំសវនាការ គឺការអនុញ្ញាតឱ្យ "ជនជាប់ចោទ លើកឡើងនូវបញ្ហាទាំងឡាយទាក់ទងនឹងស្ថានភាពផ្លូវកាយ និងផ្លូវចិត្តរបស់ខ្លួន។

## ២. វិធីសាស្ត្ររបស់អង្គបុរេជំនុំជម្រះ

១០. នៅក្នុងដំណាក់កាលស៊ើបអង្កេត អង្គបុរេជំនុំជម្រះ ("អបជ") មានឱកាសប្រកាន់យកជំហរជាក់លាក់ដើម្បីឆ្លើយតបទៅនឹងពាក្យសុំការវាយតម្លៃសម្បទា ដែលបានដាក់ដោយលោក **នួន ជា** និងលោក **អៀង សារី**។ ពាក្យសុំទាំងនេះត្រូវបានសង្ខេបដូចខាងក្រោម៖

ក. វិសាលភាពនៃវិធាន៣២ "មានន័យទូលំទូលាយគ្រប់គ្រាន់" សមស្របទៅនឹងសំណើសុំការវាយតម្លៃផ្នែកសម្បទា[២៧]។

ខ. សំណើសុំមួយដែលស្នើសុំឱ្យមានការវាយតម្លៃសម្បទា "*តាមលក្ខណៈរបស់វា* [...] តម្រូវឱ្យមានការយកចិត្តទុកដាក់ឱ្យបានទាន់ពេលវេលា"[២៨]។

គ. ដោយសារ "លិខិតបទដ្ឋានគតិយុត្តិរបស់ អវតក វិធានផ្ទៃក្នុង និងច្បាប់កម្ពុជាមិនបានកំណត់ឱ្យបានច្បាស់លាស់អំពីអត្ថន័យនៃពាក្យថា "សម្បទាចូលរួមក្នុងដំណើរការជំនុំជម្រះក្តីនោះ" អង្គបុរេជំនុំជម្រះគួរតែស្វែងរកបទដ្ឋានណែនាំលើ "បញ្ហានីតិវិធីដែលបាន

---

[២៦] *សូមមើល* វិធាន៣១(១០) ("(...) ជនជាប់ចោទ (...) ឬមេធាវីរបស់ពួកគេអាចស្នើសុំឱ្យ (...) អង្គជំនុំជម្រះចាត់តាំងអ្នកជំនាញថ្មីបន្ថែមទៀត ដើម្បីធ្វើការត្រួតពិនិត្យជាថ្មី ឬត្រួតពិនិត្យឡើងវិញលើបញ្ហាណាមួយដែលមាននៅក្នុងរបាយការណ៍របស់អ្នកជំនាញមុនរួចមកហើយ។ សំណើនេះ ត្រូវធ្វើជាលាយល័ក្ខអក្សរ និងមានបញ្ជាក់មូលហេតុ។ សំណើនេះត្រូវសម្រេចដោយ (...) អង្គជំនុំជម្រះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងមុនពេលបញ្ចប់ (...) កិច្ចដំណើរការនីតិវិធី")។

[២៧] *សូមមើល* ឯកសារលេខ A-189-I-8 អបជ "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ" ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ERN 00233433–00233443 (សាលដីកាស្តីពីសម្បទារបស់ នួន ជា) កថាខណ្ឌ២៧។ សាលដីកាស្តីពីសម្បទារបស់ នួន ជា កថាខណ្ឌ១៩។

[២៨] សាលដីកាស្តីពីសម្បទារបស់ នួន ជា កថាខណ្ឌ២២ (គូសបញ្ជាក់បន្ថែម)។

បង្កើតឡើងនៅកម្រិតអន្តរជាតិ”[២៩]។

ឃ. លក្ខណៈវិនិច្ឆ័យ*ទូទៅ* ដែលបានសម្រេចជាចម្បងនៅក្នុងរឿងក្តី *Strugar*[៣០] និង

[២៩] សាលដីកាស្តីពីសម្បទារបស់ នួន ជា កថាខណ្ឌ២៨។ សាលដីកាស្តីពីសម្បទារបស់ នួន ជា កថាខណ្ឌ២០ (ទាញសំអាងហេតុមាត្រា១២ នៃកិច្ចព្រមព្រៀង អវតក)។

[៣០] *សូមមើលរឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Strugar សំណុំរឿងលេខ IT-01-42-T “សេចក្តីសម្រេចទៅលើសំណើរបស់មេធាវីការពារក្តី សុំបញ្ឈប់កិច្ចដំណើរការនីតិវិធី” ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤ (“សេចក្តីសម្រេចក្នុងរឿងក្តី Strugar”) (ដែលក្នុងនេះ អង្គជំនុំជម្រះសាលាដំបូង II នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (“ICTY”) បានទទួលស្គាល់យ៉ាងទូលំទូលាយនូវទស្សនទានស្តីពីសម្បទាចូលរួមក្នុងការជំនុំជម្រះ ផ្តោតទៅលើសម្បទារបស់ជនជាប់ក្នុងការសារភាព ការផ្តល់សក្ខីកម្ម ការផ្តល់យោបល់ដល់មេធាវីការពារក្តីរបស់ខ្លួន និងការយល់ដឹងពីលក្ខណៈនៃចោទប្រកាន់ ព័ត៌មានលម្អិតនៃភស្តុតាង និងហេតុនិងបច្ច័យនៃកិច្ចដំណើរការនីតិវិធី)។ នៅក្នុងរឿងក្តី *Strugar* មេធាវីការពារក្តីបានដាក់សំណើសុំបញ្ឈប់កិច្ចដំណើរការនីតិវិធី ដោយមូលហេតុថា ជនជាប់ចោទដែលមានអាយុ ៧០ ឆ្នាំ មិនមានសម្បទាចូលរួមក្នុងការជំនុំជម្រះទេ ដោយសារមានជម្ងឺផ្នែករាងកាយ និងផ្លូវចិត្ត រួមមាន ជម្ងឺភ្លេចភ្លាំងដោយសារស្ទះសសៃឈាម (vascular dementia) ជម្ងឺបាក់ស្បាត (post-traumatic stress disorder) ការថប់ដង្ហើម (depression) ជម្ងឺសន្លាក់ឆ្អឹង (arthritis) និង ជម្ងឺតម្រងនោមរ៉ាំរ៉ៃ (chronic renal failure)។ *សូមមើល* សេចក្តីសម្រេចក្នុងរឿងក្តី Strugar កថាខណ្ឌ ១៣។ ជំហររបស់មេធាវីការពារក្តីគឺថា វិបល្លាសរបស់ Strugar - ទាំងដោយឡែក ទាំងការរួមបញ្ចូលគ្នា - “ប៉ះពាល់ជាអវិជ្ជមានដល់ការចងចាំ ការយកចិត្តទុកដាក់ ការផ្តង់អារម្មណ៍ អរូបិយកម្ម និងលទ្ធភាពក្នុងការគ្រប់គ្រង” ហេតុនេះគាត់ “អាចចូលរួមការពារក្តីរបស់ខ្លួនដោយមាននការលំបាកបំផុត ហើយមិនអាចផ្តល់យោបល់ដល់មេធាវីការពារក្តីរបស់គាត់អំពីការជំនុំជម្រះបានទេ”។ *ដូចជើងទំព័រខាងលើ*។ ទោះបីអង្គជំនុំជម្រះបានច្រានចោលនូវទឡ្ហីករណ៍របស់មេធាវីការពារក្តីក៏ដោយ ក៏មានការកំណត់ និងយកមកអនុវត្តនូវគោលការណ៍ជាក់លាក់នានាខាងក្រោម មុននឹងសម្រេចសេចក្តីគឺ៖ (i) ការគោរពសិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទ ដែលសន្មតយកសមត្ថភាពផ្នែកផ្លូវចិត្ត និងផ្លូវកាយអប្បរមាដើម្បីយល់ដឹងពីសិទ្ធិទាំងនោះ (ii) នៅពេលដែលសមត្ថភាពនេះត្រូវទទួលរងផលប៉ះពាល់បែបអវិជ្ជមាន ដោយវិបល្លាសផ្នែកផ្លូវចិត្ត ឬផ្លូវកាយ ការអនុវត្តនូវសិទ្ធិទាំងនោះប្រកបដោយប្រសិទ្ធិភាពត្រូវអាក់ខាន ឬរាំង (iii) សិទ្ធិទទួលបានជំនួយពីមេធាវីការពារក្តីអាចប៉ះប៉ូវដល់វិការៈផ្នែកសមត្ថភាព បានតែក្នុងករណីដែលជនជាប់ចោទអាចផ្តល់ការណែនាំពេញលេញដល់មេធាវីការពារក្តីក្នុងការចូលរួមរបស់មេធាវីការពារក្តីរបស់ខ្លួនប៉ុណ្ណោះ (iv) ក្នុងករណីមានសម្បទាមិនពេញលេញក្នុងពេលបណ្តោះអាសន្នកិច្ចដំណើរការនីតិវិធីគួរត្រូវផ្អាកសិន រហូតទាល់តែ ការខូចខាត ឬអសមត្ថភាពនោះត្រូវបានដោះស្រាយឱ្យបានសមរម្យ (v) បទដ្ឋានស្តីពីភស្តុតាងត្រូវបានតុល្យភាពនៃភាពទំនង (vi) ការសម្រេចចិត្តត្រូវតែពឹងផ្អែកលើទស្សនៈរបស់អ្នកជំនាញដែលពាក់ព័ន្ធ ដែលផ្តល់ និងត្រួសត្រាយដោយបទដ្ឋានផ្លូវច្បាប់ដែលមានជា ធរមាន។ *ដូចជើងទំព័រខាងលើ* កថាខណ្ឌ21-24, 38-39, 46-49។

*Stanisic*[៣១] និង ករណីដែលថ្មីៗស្រាយជាងនេះ គឺរឿងក្តី *Nahak*[៣២] ("លក្ខណៈវិនិច្ឆ័យក្នុង

---

[៣១] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Stanisic *និង* Simatovic, សំណុំរឿងលេខ IT-03-69 "សេចក្តីសម្រេចលើសំណើសុំរបស់មេធាវីការពារក្តី Stanisic ស្តីពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមក្នុងការជំនុំជម្រះក្តី ដោយមានឧបសម្ព័ន្ធដែលត្រូវរក្សាជាការសម្ងាត់" ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៦ ("សេចក្តីសម្រេចលើរឿងក្តី Stanisic")។

[៣២] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Josep Nahak*, សំណុំរឿងលេខ 01A/2004, "សំអាងហេតុ និងដីកាសម្រេចទៅលើសម្បទារបស់ចុងចោទ Nahak ក្នុងការចូលរួមក្នុងការជំនុំជម្រះក្តី" ចៅក្រម Philip Rapoza ថ្ងៃទី១ ខែមីនា ឆ្នាំ២០០៥ ("សេចក្តីសម្រេចលើរឿងក្តី Nahak") កថាខណ្ឌ២៤ (ដែលក្រុមប្រឹក្សាចៅក្រមពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅប្រទេសទីម័រខាងកើត (តុលាការស្រុកឌីលី) បានសម្រេចថា "បទដ្ឋានដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ" តម្រូវឱ្យមានការវាយតម្លៃពីសម្បទា (រួមទាំងសវនាការ និងការសម្រេចរបស់តុលាការ) "នៅពេលដែលបញ្ហាសមត្ថភាពរបស់ចុងចម្លើយក្នុងការចូលរួមក្នុងការជំនុំជម្រះក្តីត្រូវបានលើកឡើង")។ នៅក្នុងរឿងក្តី *Nahak* តុលាការយល់ឃើញថា សំអាងហេតុដើម្បីឱ្យមានការវាយតម្លៃពីសម្បទាមានបីចំណុច៖ (i) *គោរពយល់សិទ្ធិជាសារវន្តរបស់ជនជាប់ចោទក្នុងការមានមេធាវីការពារក្តី និងមានពេលវេលាពេញលេញ និងសម្ភារៈគ្រប់គ្រាន់សម្រាប់រៀបចំការការពារខ្លួន៖* "ប្រសិនបើចុងចម្លើយមិនមាន [សមត្ថភាពយល់ដឹង និងអនុវត្តសិទ្ធិទាំងនេះ] សិទ្ធិជាសារវន្តទាំងនោះក៏មិនមានខ្លឹមសារអ្វីដែរ" (ii) *ការហាមឃាត់មិនឱ្យមានការជំនុំជម្រះក្តីកំបាំងមុខ៖* "ទោះបីមានវត្តមានផ្នែករាងកាយនៅក្នុងបន្ទប់សវនាការក៏ដោយ ក៏ការពិត [ជនជាប់ចោទដែលមិនបានសម្បទាពេញលេញ] បណ្តាលឱ្យគាត់មិនអាចការពារខ្លួនបាន" និង (iii) *សុច្ចរិតភាពនៃដំណើរការក្នុងតុលាការ៖* "ក្នុងកាលៈទេសៈដែលចុងចម្លើយមិនអាចយល់បានពីលក្ខណៈនៃកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងរូបគាត់ គាត់មិនអាចពិភាក្សាជាមួយមេធាវីការពារក្តីរបស់ខ្លួនបាន ឬមិនអាចជួយរៀបចំការការពារខ្លួនបាន នោះលទ្ធផលនៃការជំនុំជម្រះក្តីទំនងមិនមានភាពយុត្តិធម៌ ឬសុក្រឹតភាពឡើយ។ សង្គមមានការចាប់អារម្មណ៍ក្នុងការធានាថា ការផ្តន្ទាទោសចុងចោទណាម្នាក់ មិនមែនជាលទ្ធផលនៃការមិនអាចជួយគាត់បាននៅក្នុងពេលជំនុំជម្រះក្តីទេ"។ សេចក្តីសម្រេចលើរឿងក្តី Nahak កថាខណ្ឌ38, 46, 48។ ដើម្បីឱ្យការវាយតម្លៃបែបនេះ "អាចធ្វើទៅបានក្នុងកម្រិតមួយដែលមានការសង្ស័យពីសមត្ថភាពរបស់ចុងចោទ ក្នុងការចូលរួមក្នុងការជម្រះក្តី" និង "កម្រិតនៃកង្វល់របស់តុលាការទាក់ទិននឹងសមត្ថភាពរបស់ចុងចោទត្រូវតែយកចិត្តទុកដាក់ខ្ពស់"។ *ដូចដើងទំព័រខាង* កថាខណ្ឌ 49, 50។ ជនជាប់ចោទមានសម្បទាក្នុងការចូលរួមក្នុងការជម្រះក្តី ប្រសិនបើគាត់មាន៖ (១) សំអាងហេតុមួយរួមទាំងការយល់ដឹងពីអង្គហេតុនៃបទចោទប្រឆាំងនឹងគាត់ (២) សំអាងហេតុរួមទាំងការយល់យល់ដឹងពីអង្គហេតុនៃលក្ខណៈ និងកម្មវត្ថុនៃកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ និង (៣) លទ្ធភាពនាពេលបច្ចុប្បន្នក្នុងការពិភាក្សាជាមួយមេធាវីការពារក្តីរបស់គាត់ និងជួយក្នុងការរៀបចំការពារខ្លួន ដោយមានការយល់ដឹងពីសំអាងហេតុក្នុងកម្រិតមួយសមហេតុសមផល"។ *ដូចដើងទំព័រខាងលើ* កថាខណ្ឌ៥៤។ (*កំណត់សម្គាល់ពិសេស៖* នេះជាពិសោធន៍ដែលបានអនុម័តយកជាសារវន្តដោយតុលាការកំពូលសហរដ្ឋអាមេរិក ក្នុងរឿងក្តី *Dusky តទល់នឹង* សហរដ្ឋអាមេរិក សំណុំរឿងលេខ 362 US 402 (ឆ្នាំ១៩៦០) វាមិនខុសពីទម្រង់នៅក្នុងរឿងក្តី *Strugar* ទេ តាមវិធីដែលមានន័យ)។ ការវិភាគទៅលើសម្បទា "ជាការសម្រេចចិត្តផ្នែកច្បាប់ មិនមែនតាមផ្នែកវិទ្យាសាស្ត្រ" ទេ។ សេចក្តីសម្រេចលើរឿង Nahak កថាខណ្ឌ 120។ "ចុងចោទដែលមិនអាចធ្វើអ្វីបានក្រៅតែពីយល់ស្របជាមួយមេធាវីការពារក្តីរបស់ខ្លួន ដោយសារខ្លួនមិនមានសមត្ថភាពធ្វើអ្វីផ្សេងបាន មិនអាចចាត់ទុកថា គាត់មានសមត្ថភាពបានទេ ទោះបីតំណាងដោយមេធាវីការពារក្តីរបស់ខ្លួនក៏ដោយ"។ *ដូចដើងទំព័រខាងលើ* កថាខណ្ឌ132។

រឿងក្តី *Strugar*") គឺ "ថាតើមានមូលហេតុគ្រប់គ្រាន់ឬទេ ក្នុងការចោទសួរពីសមត្ថភាពរបស់ជនត្រូវចោទក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី និងថាតើជនជាប់ចោទអនុវត្តសិទ្ធិរបស់ខ្លួនឲ្យបានពេញលេញឬទេ ក្នុងអំឡុងពេលស៊ើបអង្កេត ដោយមានជំនួយពីសហមេធាវីរបស់ខ្លួន"[៣៣]។

ង. មេធាវីការពារក្តីមានបន្ទុកក្នុងការធ្វើយុត្តិកម្មឲ្យមានការតែងតាំងសាក្សីអ្នកជំនាញ[៣៤]។

១១. ទាក់ទិននឹងអត្ថន័យជាក់លាក់នៃឃ្លាថា "មានសម្បទាក្នុងការចូលរួមក្នុងការជំនុំជម្រះក្តី" អបជ បានសម្រេចយ៉ាងច្បាស់លាស់យកតាមលក្ខណៈវិនិច្ឆ័យនៅក្នុងរឿងក្តី *Strugar* ថា៖

> អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក៏បានយល់ឃើញនៅក្នុងរឿងក្តី *Strugar* ថា សម្បទារបស់បុគ្គលណាម្នាក់ក្នុងការចូលរួមក្នុងសវនាការ ជុំវិញសមត្ថភាពរបស់គាត់ "ដើម្បីឆ្លើយតប ដើម្បីយល់ដឹងពីលក្ខណៈនៃបទចោទប្រកាន់ ដើម្បីយល់ពីដំណាក់កាលនានានៃកិច្ចដំណើរការនីតិវិធី ដើម្បីយល់ដឹងពីចំណុចពិស្តារនៃភស្តុតាង ដើម្បីផ្តល់សេចក្តីណែនាំដល់ក្រុមមេធាវីការពារក្តី ដើម្បីយល់ដឹងពីផលវិបាកនៃកិច្ចដំណើរការនីតិវិធី និងដើម្បីផ្តល់សក្ខីកម្ម"[៣៥]។

ទោះបីជាយ៉ាងក្តី វិសាលភាពដែល អបជ ពិចារណាពីយុត្តិសាស្ត្រដែលពាក់ព័ន្ធ និង/ឬ ទ្រឹស្តីរបស់អ្នកប្រាជ្ញមុនៗដើម្បីប្រកាន់យកជំហរនេះ គឺពុំសូវមានភាពច្បាស់លាស់ប៉ុន្មានទេ។ ដោយសារថាការយល់ឃើញបែបនេះពិតជានឹងអាចជួយអង្គជំនុំជម្រះសាលាដំបូង ក្នុងការបង្កើតជាលក្ខណៈវិនិច្ឆ័យទៅលើសម្បទា ដែលផ្តល់យុត្តិធម៌ចំពោះកិច្ចដំណើរការនីតិវិធី ដែលអាចអនុវត្តនៅក្នុងសំណុំរឿង០០២ នៅ អវតក នោះហើយ ទើបមេធាវីការពារក្តីយល់ឃើញថា វាជាការសំខាន់ដែលត្រូវដាក់ជូនសារណាបន្ថែមនានាដូចខាងក្រោមនេះ។

---

[៣៣] សាលដីកាស្តីពីសម្បទារបស់ អៀង សារី កថាខណ្ឌ៤១។ សាលដីកាស្តីពីសម្បទារបស់ នួន ជា កថាខណ្ឌ៣៥។

[៣៤] សាលដីកាស្តីពីសម្បទារបស់ អៀង សារី កថាខណ្ឌ៤៦ (អបជ សន្និដ្ឋានថា "គ្មានហេតុផលត្រឹមត្រូវណាមួយ ដើម្បីចាត់តាំងអ្នកជំនាញផ្នែកវិកលចរិកឡើយ") សាលដីកាស្តីពីសម្បទារបស់ នួន ជា កថាខណ្ឌ៤១ ("សំណើសុំចាត់តាំងអ្នកជំនាញដើម្បីធ្វើការវាយតម្លៃសម្បទារបស់ជនត្រូវចោទក្នុងការចូលរួមក្នុងការជំនុំជម្រះ និងសមត្ថភាពរបស់គាត់ក្នុងការចូលរួមដោយប្រសិទ្ធិភាពនៅក្នុងការការពារខ្លួន មិនមានមូលហេតុត្រឹមត្រូវឡើយ")។ *កំណត់សម្គាល់ពិសេស៖* ដោយផ្អែកលើមូលដ្ឋាននៃអង្គហេតុ អបជ បានបញ្ជាក់ពីការច្រានចោលនូវសំណើសុំទាំងពីរ។

[៣៥] សាលដីកាស្តីពីសម្បទារបស់ នួន ជា កថាខណ្ឌ២២ (ទាញសំអាងហេតុពីសេចក្តីសម្រេចលើរឿងក្តី Strugar កថាខណ្ឌ៣៦)។

## ៣. *វិធីសាស្ត្រផ្សេងៗទៀត*

១២. ការកែលំអលក្ខណៈវិនិច្ឆ័យយ៉ាងទូលំទូលាយ ដែលមានរៀបរាប់នៅក្នុងរឿងក្តី *Strugar* មានចែងពីវិធីសាស្ត្រមួយចំនួនដើម្បីឆ្លើយតបនឹងបញ្ហាសម្បទាដើម្បីចូលរួមក្នុងសវនាការ ឧទាហរណ៍៖ លក្ខណៈវិនិច្ឆ័យសាកសួរអំពីសម្បទា - អត្ថបទដែលបានកែប្រែ (“លក្ខណៈវិនិច្ឆ័យសាកសួរអំពីសម្បទា”)[៣៦] វិធីសាស្ត្រក្នុងការវាយតម្លៃពីសមត្ថភាព MacArthur - ការវិនិច្ឆ័យទោសព្រហ្មទណ្ឌ (“លក្ខណៈវិនិច្ឆ័យ MacArthur”)[៣៧] និង លក្ខណៈវិនិច្ឆ័យដែលរៀបចំឡើងដោយតុលាការជាន់ខ្ពស់អូស្ត្រាលី (“លក្ខណៈវិនិច្ឆ័យតាមរបៀបអូស្ត្រាលី”)[៣៨]។ ជាពិសេស លក្ខណៈវិនិច្ឆ័យទាំងនេះឆ្លើយតបទៅនឹងកត្តានានាដូចខាងក្រោម កាន់តែយ៉ាងពិស្តារ៖

ក. *ការយល់ដឹងរបស់ជនជាប់ចោទ ពីអង្គហេតុ និងប្រកបដោយហេតុផល នៅក្នុងកិច្ចដំណើរការនីតិវិធី៖*

ចំណុចនេះរួមមានការគោរពដល់៖ សិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទ (ឧ. ផ្តល់ភស្តុតាងពីភាពស្លូតត្រង់ និងការជំទាស់ទៅនឹងការចោទប្រកាន់ រក្សាភាពស្ងៀមស្ងាត់ ការការពារប្រឆាំងនឹងការផ្តល់សក្ខីកម្មប្រឆាំងខ្លួនឯង លទ្ធភាពនៃការប្តឹងឧទ្ធរណ៍) យុត្តិធម៌ដែលតុលាការផ្តល់ឱ្យគាត់ តួនាទីរបស់ចៅក្រម រដ្ឋអាជ្ញា និងក្រុមមេធាវីការពារក្តី លក្ខណៈ និងគុណសម្បត្តិនៃជំនួយដែលផ្តល់ដោយក្រុមមេធាវីការពារក្តីរបស់គាត់ ការរំពឹងទុកថាជនជាប់ចោទគួរផ្តល់ការណែនាំឱ្យបានពេញលេញដល់ក្រុមមេធាវីការពារក្តី ធាតុផ្សំនៃបទល្មើសដែលបានចោទប្រកាន់ ការសារភាពទទួលស្គាល់ទោសដែលអាចកើតឡើង បន្ទុក/បទដ្ឋាន នៃភស្តុតាង/ការបញ្ចុះបញ្ចូល ដែលអាចអនុវត្តបាន ការជាប់ពាក់ព័ន្ធដែល

---

៣៦ *សូមមើល* R Roesch, PA Zapf, SL Golding & JL Skeem, *ការកំណត់និយមន័យ និងការវាយតម្លៃអំពីសមត្ថភាពចូលរួមក្នុងសវនាការ នៅក្នុង IB Weiner & A K Hess (Eds), កូនសៀវភៅស្តីពីកោសល្យវិច័យចិត្តសាស្ត្រ បោះពុម្ពលើកទីពីរ (Wiley 1999) ទំព័រ ១១ ដល់ ១២។ D Nussbaum, M Hancock, I Turner, J Arrowood, S Melodick, សម្បទា/សមត្ថភាពចូលរួមក្នុងសវនាការ, ទស្សនទានទូទៅ, ការពិនិត្យឯកសារដែលមានស្រាប់ឡើងវិញ និងការសាកសួរអំពីសុពលភាពនៃសំណួរស្តីពីសម្បទារបស់* the Nussbaum (Oxford 2007) *Subramaniam v The Queen* [2004] HCA 21, 211 ALR 1, at 40–41 *៥១ ដល់ ៥៣។*

៣៧ *សូមមើល* Roesch *និងអ្នកផ្សេងទៀត លេខយោងជើងទំព័រ ៣៧ ខាងលើ ទំព័រ ៥៣ ដល់ ៥៨។*

៣៨ *សូមមើល* [រឿងក្តី *Subramaniam* *តទល់នឹង មហាក្សត្រិយានី* [ឆ្នាំ២០០៤] សំណុំរឿងលេខ HCA 21, 211 ALR 1, ត្រង់ទំព័រ ៤០ ដល់ ៤១ ។

00641450



មាននៅក្នុងសក្ខីកម្ម (ទាំងសក្ខីកម្មរបស់ជនជាប់ចោទ និងអ្នកដទៃទៀត) គោលការណ៍នៃការដាក់ទោសអាចអនុវត្តទៅបាន រួមទាំងភវនីយហេតុ និងភាពធ្ងន់ធ្ងរនៃការដាក់ទោសសំខាន់ៗណាមួយ[៣៩]។

ខ. *សមត្ថភាពរបស់ជនជាប់ចោទក្នុងការផ្តល់សក្ខីកម្ម៖*

ចំណុចនេះរួមទាំងលទ្ធភាពរបស់គាត់ក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ទៅតាមលក្ខណៈមួយដែលទទួលបានព័ត៌មានគ្រប់គ្រាន់ និងប្រកបដោយស្ថាបនា[៤០] រួមទាំងសមត្ថភាពរបស់ខ្លួនក្នុងការគិត ការផ្តង់អារម្មណ៍ និងការនិយាយដោយមានសំអាងត្រឹមត្រូវ ដោយស្ងប់ស្ងៀម និងប្រកបដោយហេតុផលនៅក្នុងតុលាការ[៤១]។

គ. *សមត្ថភាពរបស់ជនជាប់ចោទក្នុងការផ្តល់ការណែនាំដល់ក្រុមមេធាវីការពារក្តី៖*

ដូចបានពន្យល់យ៉ាងច្បាស់នៅក្នុងរឿងក្តី *Strugar* រួចមកហើយថា សមត្ថភាពនេះអាចត្រូវបានវាយតម្លៃអាស្រ័យទៅលើលក្ខណៈវិនិច្ឆ័យនានាដូចជា៖ ការយល់ដឹងរបស់ជនជាប់ចោទពីមូលដ្ឋានសម្រាប់ក្រុមមេធាវីការពារក្តីរបស់ខ្លួន និងលទ្ធភាពរបស់គាត់ក្នុងការដឹងពីព័ត៌មានថ្មីៗ ការរំឭកឡើងវិញនូវព័ត៌មានដែលសមហេតុសមផល ការផ្តង់អារម្មណ៍ ការយកចិត្តទុកបានក្នុងរយៈពេលយូរ និងការដឹងពីផលវិបាកនៃការចូលរួមរបស់ខ្លួននៅក្នុងតុលាការ[៤២]។ ការអធិប្បាយបន្ថែមទៀត រួមមាន លទ្ធភាពរបស់ជនជាប់ចោទក្នុងការទំនាក់ទំនងការងារជាមួយមេធាវីការពារក្តីរបស់ខ្លួន ការផ្តល់អង្គហេតុដល់ក្រុមមេធាវីការពារក្តី ការរៀបចំផែនការយុត្តិសាស្ត្រតាមផ្លូវច្បាប់ និងការចូលរួមតាមវិធីផ្សេងទៀតជាមួយក្រុមមេធាវីការពារក្តីរបស់ខ្លួន[៤៣]។ ដោយឡែក ចំណុចនេះរួមមានសមត្ថភាពផ្លូវចិត្ត ដើម្បីការផ្តល់ការណែនាំដល់មេធាវីការពារក្តីអំពីលក្ខណៈដែលថាភស្តុតាងផ្ទុយត្រូវបានវាយតម្លៃឲ្យបានត្រឹមត្រូវបំផុត[៤៤]។

---

៣៩ *សូមមើល* លក្ខណៈវិនិច្ឆ័យ McArthur។

៤០ *សូមមើល* លក្ខណៈវិនិច្ឆ័យ តាមរបៀបអូស្ត្រាលី។

៤១ សេចក្តីសម្រេចលើរឿងក្តី Strugar។

៤២ *សូមមើល* សេចក្តីសម្រេចលើរឿងក្តី Strugar កថាខណ្ឌ ៤៩។

៤៣ *សូមមើល* លក្ខណៈវិនិច្ឆ័យដើម្បីធ្វើសម្ភាសផ្នែកសម្បទា, លក្ខណៈវិនិច្ឆ័យតាមបែបអូស្ត្រាលី។

៤៤ *សូមមើល* លក្ខណៈវិនិច្ឆ័យដើម្បីធ្វើសម្ភាសផ្នែកសម្បទា, លក្ខណៈវិនិច្ឆ័យតាមបែបអូស្ត្រាលី។

១៣. ប្រការនេះមិនមែនជាការចាំបាច់ដែលត្រូវបង្ហាញពីបញ្ជីដែលរៀបរាប់ពីលក្ខណៈវិនិច្ឆ័យដ៏ច្រើននោះទេ។ ការវាយតម្លៃពីសម្បទាដែលអាចយល់ដឹងបានយ៉ាងទូលំទូលាយ គួរបញ្ចូលនូវការរកឃើញ និងការវាយតម្លៃពីចំណុចនានាដូចជា៖ ការរំខានក្នុងអារម្មណ៍ មនសិការ ការប្រាស្រ័យទាក់ទង និង/ឬ ការចងចាំ ដំណើរការដែលប្រកបការបំភាន់ភ្នែក ការរវើរវាយ ឥរិយាបថដែលមិនអាចគ្រប់គ្រងបាន ឬជាការឱ្យរំខាន ភាពយឺតយ៉ាវផ្នែកស្មារតី និង/ឬ ការអន់ខ្សោយជាទូទៅក្នុងការវិនិច្ឆ័យ និងការយល់ដឹងឱ្យបានច្បាស់លាស់[៤៥] រួមទាំងបញ្ហាថាតើការប្រើប្រាស់ថ្នាំពេទ្យ ឬការព្យាបាលតាមវិធីណាមួយគឺជាការចាំបាច់ដើម្បីរក្សាសមត្ថភាព និងប្រសិទ្ធភាពក្នុងការយកចិត្តទុកដាក់ នៃវិធានការបែបនេះចំពោះអាកប្បកិរិយា ផលប៉ះពាល់ និងលទ្ធភាពដែរឬយ៉ាងណានោះ[៤៦]។

១៤. នៅក្នុងការវិភាគចុងក្រោយ លក្ខណៈវិនិច្ឆ័យទៅលើសម្បទាដែលសមស្រប ដែលត្រូវបានយកមកអនុវត្តនោះ គឺលក្ខណៈវិនិច្ឆ័យដែលច្របាច់បញ្ចូលគ្នានូវលក្ខណៈវិនិច្ឆ័យពាក់ព័ន្ធ*ទាំងអស់* និងឆ្លុះបញ្ចាំងពីអត្តចរិតណាមួយរបស់ជនជាប់ចោទ រួមទាំងលក្ខណៈពិសេសនៃកិច្ចដំណើរការនីតិវិធី។ ដោយសារអត្ថន័យនៃពាក្យសម្បទាក្នុងការចូលរួមក្នុងសវនាការ មានការប្រែប្រួលទៅតាមបរិបទខ្លាំងពេក នោះការវាយតម្លៃពាក្យនេះ គឺអាស្រ័យទៅលើភាពធ្ងន់ធ្ងរ និងភាពស្មុគ្រស្មាញនៃបទចោទការជំទាស់តវ៉ានានាប្រឆាំងនឹងជនជាប់ចោទនៅក្នុងករណីនោះ និងទំនាក់ទំនងរវាងរូបគាត់ និងក្រុមមេធាវីការពាររបស់គាត់[៤៧]។ នៅក្នុងការវាយតម្លៃបែបនេះ តុលាការគួរពិចារណាទៅលើអាយុ សមត្ថភាពយល់ដឹង និងស្ថានភាពសុខភាពរបស់ជនជាប់ចោទ ដោយមានគោលបំណងសំខាន់បំផុតក្នុងការបង្កើនការយល់ដឹងឱ្យបានប្រសើរឡើង និងការចូលរួមនៅក្នុងដំណើរការសវនាការដែលមានភាពស្មុគ្រស្មាញ។

### *៤. បន្ទុក និងបទដ្ឋាននៃភស្តុតាង*

---

[៤៥] *សូមមើល* SL Golding *សៀវភៅណែនាំសម្រាប់ការបណ្តុះបណ្តាល, Interdisciplinary Fitness Interview-Revised: សាកលវិទ្យាល័យ* Utah, ផ្នែកចិត្តសាស្ត្រ (ឆ្នាំ១៩៩៣) ។

[៤៦] *សូមមើល* (Utah Code Annotated §77-15-5 (ឆ្នាំ១៩៩៤))។

[៤៧] *សូមមើល* (Freckelton, I, "សំអាងហេតុ និងភាពបត់បែនក្នុងការវាយតម្លៃពីសម្បទាក្នុងការចូលរួមក្នុងការជំនុំជម្រះ" ('Rationality and Flexibility in Assessment of Fitness to Stand Trial') *19 International Journal of Law and Psychiatry ឆ្នាំ១៩៩៦* ទំព័រ៤៨)។

១៥. វិធីសាស្ត្ររបស់ អបជ បង្ហាញថា មេធាវីការពារក្តីជាអ្នកទទួលខុសត្រូវក្នុងការស្វែងរកបន្ទុកនៃភស្តុតាង[៤៨]។ ទោះជាយ៉ាងណាក្តី នៅក្នុងរឿងក្តី *Nahak* តុលាការបានចាត់ទុកថា វិធីសាស្ត្របែបនេះមិនឆ្លុះបញ្ចាំងពីការអនុវត្តជាទូទៅ និងជាទម្លាប់អនុវត្តអន្តរជាតិទេ[៤៩]។ ដោយមិនដាក់បន្ទុកទៅលើភាគីណាមួយនោះ ចៅក្រម Riposa បានសន្និដ្ឋានថា ដោយសារមិនមានភាពច្បាស់លាស់នៅក្នុងបញ្ហានេះ នោះដើម្បីជាប្រយោជន៍នៃយុត្តិធម៌ តុលាការត្រូវសម្រេចទៅលើបញ្ហានេះ ដោយមិនគិតដល់ការដាក់បន្ទុកពិសេសណាមួយទៅលើចុងចោទតាមវិធីផ្សេងទៀតឡើយ[៥០]។ បទដ្ឋាននៃស្តុតាងដែលត្រូវបានទទួលស្គាល់ជាទូទៅ គឺជាតុល្យភាពនៃភវនីយហេតុ[៥១]។ អាចនិយាយម្យ៉ាងទៀតថា ដើម្បីដំណើរការទៅបាន លុះត្រាតែជនជាប់ចោទមានសម្បទា ចូលរួមក្នុងការជំនុំជម្រះក្តីច្រើនជាងមិនមាន។

## ៥. ផលវិបាកនៃការមិនមានសម្បទា

១៦. ដូចបានកត់សម្គាល់នៅក្នុងរឿងក្តី *Strugar* រួចមកហើយថា "ផលវិបាកនៃការរកឃើញថាជនជាប់ចោទមិនមានសម្បទាចូលរួមក្នុងការជំនុំជម្រះក្តី គឺមានភាពខុសៗគ្នាទៅតាមកាលៈទេសៈនីមួយៗ"[៥២]។ ដោយអាស្រ័យទៅលើភាពធ្ងន់ធ្ងរនៃអសមត្ថភាពណាមួយ ដំណោះស្រាយមិនសមរម្យអាចនឹងបង្កើតឲ្យមានភាពរអាក់រអួល[៥៣] គឺការផ្អាកកិច្ចដំណើរការនីតិវិធី ដើម្បីរង់ចាំការព្យា

[៤៨] *សូមមើល* សេចក្តីសម្រេចលើរឿងក្តី Strugar កថាខណ្ឌ៣៨។

[៤៩] *សូមមើល* សេចក្តីសម្រេចលើរឿងក្តី Nahak កថាខណ្ឌ៦៦។

[៥០] *សូមមើល* សេចក្តីសម្រេចលើរឿងក្តី Nahak កថាខណ្ឌ៦៧។

[៥១] *សូមមើល* សេចក្តីសម្រេចលើរឿងក្តី Strugar កថាខណ្ឌ៣៨។

[៥២] សេចក្តីសម្រេចលើរឿងក្តី Strugar កថាខណ្ឌ៣៩ ("មិនទាន់មានច្បាប់ ឬមូលដ្ឋានណាមួយដើម្បីបន្តការជំនុំជម្រះ [នៅចំពោះមុខតុលាការ ICTY") ឡើយ នៅពេលដែលជនជាប់ចោទមិនមានសម្បទាក្នុងការចូលរួមក្នុងការជំនុំជម្រះ។ ជាងនេះទៀត ក្នុងករណីដែលភាពមិនមានសម្បទាក្នុងការចូលរួមក្នុងការជំនុំជម្រះ ជាស្ថានភាពបណ្តោះអាសន្ន អាចនឹងមានការផ្អាកការជំនុំជម្រះ ហើយបន្តការជំនុំជម្រះទៀតនៅពេលដែលជនជាប់ចោទបានជាសះស្បើយឡើងវិញ។ ករណីផ្សេងទៀតអាចតម្រូវថា ត្រូវផ្អាកការជំនុំជម្រះតែម្តង។ អាចនឹងមានករណីដែលថា ការខូចខាតសមត្ថភាពតាមលក្ខណៈ និងផលប៉ះពាល់បែបនេះ គេត្រូវចាត់វិធានការដើម្បីលុបបំបាត់នូវការខូចខាត ឬផលប៉ះពាល់នេះ ដើម្បីឲ្យការជំនុំជម្រះអាចបន្តទៀតបាន។

[៥៣] នៅក្នុងករណីដែលមិនមានឱកាសក្នុងការកែប្រែស្ថានភាពឲ្យបានប្រសើរទេ កិច្ចដំណើរការនីតិវិធីគួរតែត្រូវបញ្ចប់។ *សូមមើល* សេចក្តីសម្រេចលើរឿងក្តី Strugar កថាខណ្ឌ ១៩ និង ៣៩ (ទោះបីមិនមានការបញ្ជាក់ច្បាស់លាស់នៅក្នុងលក្ខន្តិកៈ

បាល និងការធូរស្បើយពីជំងឺសិន[៥៤] ឬ ការរៀបចំកិច្ចដំណើរការនីតិវិធីដែលខ្លី/ត្រូវបានកែសម្រួលដើម្បីសម្របទៅតាមសមត្ថភាពមានកម្រិតរបស់ជនជាប់ចោទ[៥៥]។ ក្នុងករណីណាក៏ដោយ មិនមានមូលដ្ឋានសម្រាប់សវនាការណាមួយ "ដើម្បីបន្តទៅទៀតនោះទេ នៅពេលដែលជនជាប់ចោទមិនមានសម្បទាចូលរួមនោះ"[៥៦]។ និយាយម្យ៉ាងទៀត កម្រិតនៃការមានសម្បទាត្រូវតែធ្វើឲ្យប្រសើរឡើងដើម្បីបន្តដំណើរការនីតិវិធី។ តុលាការព្រហ្មទណ្ឌអន្តរជាតិនានាបានពិចារណាជាពិសេសទៅលើស្ថានភាពសុខភាពរបស់ចុងចោទដែលមានវ័យចំណាស់ និងទ្រុឌទ្រោម ហើយបានកែប្រែកម្មវិធីសវនាការទៅតាមនោះដែរ នៅពេលដំណើរការជំនុំជម្រះក្តីបានគំរាមគំហែងធ្វើឲ្យស្ថានភាពសុខភាពបច្ចុប្បន្នកាន់តែមានសភាពធ្ងន់ធ្ងរឡើងៗនោះ[៥៧]។

## ខ. សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយមានវត្តមានរបស់ជនជាប់ចោទ

១៧. សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយមានវត្តមានរបស់ជនណាម្នាក់ ត្រូវបានទទួលស្គាល់ជាសាកលថា ជាគោលការណ៍ចម្បងបំផុតមួយនៃសវនាការ ក្នុងចំណោមគោលការណ៍ជាច្រើន ចំពោះការជំនុំជម្រះលើរឿងក្តីព្រហ្មទណ្ឌប្រកបដោយយុត្តិធម៌[៥៨]។ សិទ្ធិនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងវិធានផ្ទៃក្នុងដែលចែងថា "ការជម្រះក្តីត្រូវតែធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ លើកលែង

---

របស់តុលាការ ICTY វិធាននានា ឬយុត្តិសាស្ត្រក៏ដោយ តែភាគីទាំងពីរយល់ស្របគ្នាថា ប្រសិនបើរកឃើញថា ជនជាប់ចោទមិនមានសម្បទាពេញលេញទេនោះ ការជំនុំជម្រះគួរតែត្រូវបញ្ចប់)។ *សូមមើលផងដែរ រឿងក្តី R តទល់នឹង រដ្ឋមន្ត្រីក្រសួងសន្តិសុខផ្ទៃក្នុង ដោយអវត្តមាន រាជាណាចក្រប៊ែលហ្សិក និង រឿងក្តី R. តទល់នឹង រដ្ឋមន្ត្រីក្រសួងសន្តិសុខផ្ទៃក្នុង ដោយអវត្តមាន អង្គការលើកលែងទោសអន្តរជាតិ និង អ្នកដាក់ពាក្យសុំប្រាំរូបផ្សេងទៀត* ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០

[៥៤] *សូមមើល* សេចក្តីសម្រេចលើរឿងក្តី Strugar កថាខណ្ឌ៣៩។

[៥៥] *សូមមើល* សេចក្តីសម្រេចលើរឿងក្តី Strugar កថាខណ្ឌ៣៩។

[៥៦] សេចក្តីសម្រេចលើរឿងក្តី Strugar កថាខណ្ឌ៣៩។

[៥៧] *សូមមើល ឧទាហរណ៍ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milosevic* សំណុំរឿងលេខ IT-02-54-T "សំអាងហេតុសម្រាប់ចេញសេចក្តីសម្រេចស្តីពីការតែងតាំងមេធាវីការពារក្តី" ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៤, កថាខណ្ឌ៥៣, *ដូចជើងទំព័រខាងលើ* 'សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ ជំទាស់នឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការតែងតាំងមេធាវីការពារក្តី" ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៤ កថាខណ្ឌ៦។

[៥៨] *សូមមើល ឧទាហរណ៍ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Zigiranyirazo* សំណុំរឿងលេខ ICTR-2001-73-AR73 "សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ" ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៦ ("សាលដីកាលើរឿងក្តី Zigiranyirazo") កថាខណ្ឌ១១។

តែមានបញ្ញត្តិផ្សេងចែងក្នុងវិធាននេះ"[៥៩]។ អនុលោមតាមយុត្តិសាស្ត្រដែលពាក់ព័ន្ធ ពាក្យថា "មានវត្តមាន" មានន័យថា *ការចូលរួមដោយរូបកាយនៅក្នុងការជំនុំជម្រះក្តី*[៦០]។

១៨. សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយមានវត្តមានរបស់ជនជាប់ចោទ មិនមែនជាសិទ្ធិដាច់ខាតនោះទេ។ សិទ្ធិនេះអាចត្រូវបានលះបង់វិញបាន ឬអាចត្រូវបានដកហូតក្នុងករណីដែលឥរិយាបថរបស់ចុងចោទបង្ហាញពីការរំខានជាខ្លាំងដល់សវនាការ[៦១]។ ទោះជាយ៉ាងណាក្តី ការរំខានណាដែលមិនបានបង្កឡើងដោយចេតនាពីជនជាប់ចោទ ដូចជាជំងឺ ឬអសមត្ថភាពផ្នែករាងកាយ/ស្មារតីដទៃទៀត[៦២] មិនអាចត្រូវបានយកមកប្រើដើម្បីធ្វើយុត្តិកម្មថា ជាការរំខានដល់ការប្រើប្រាស់សិទ្ធិក្នុងការទទួលការជំនុំជម្រះដោយមានវត្តមានរបស់ជនជាប់ចោទនោះទេ[៦៣]។ នៅក្នុងតុលាការនេះ ការលើកលែងចំពោះវិធានទូទៅត្រូវបានផ្តល់ *តែ*ក្នុងករណីដែលជនជាប់ចោទ៖ (i) "បដិសេធ ឬខកខានមិនបានចូលរួមក្នុងកិច្ចដំណើរការនីតិវិធី"[64] (ii) "ត្រូវបានបណ្តេញចេញពីកិច្ចដំណើរការនីតិវិធីដោយអនុលោមតាមវិធានផ្ទៃក្នុងនេះ"[65] ឬ (iii) "មានមូលហេតុអំពីស្ថានភាពសុខភាព ឬ មូលហេតុធ្ងន់ធ្ងរដទៃទៀត [...] មិនអាចមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបាន" *និង* យល់ព្រមឲ្យ "បន្តនីតិវិធីដោយមិនមានវត្តមានរបស់ខ្លួន"[៦៦]។

---

[៥៩] វិធាន៨១(១)។

[៦០] *សូមមើល* សាលដីកាលើរឿងក្តី Zigiranyirazo កថាខណ្ឌ១១។ *រឿងក្តី រដ្ឋអាជ្ញាតទល់នឹង Karemera* និងអ្នកដទៃទៀត, សំណុំរឿងលេខ ICTR-98-44-AR73.10 "សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំរបស់ Nzirorera ពាក់ព័ន្ធនឹងសិទ្ធិរបស់គាត់ក្នុងការមានវត្តមាននៅពេលជំនុំជម្រះ" ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៧ (សាលដីកាលើរឿងក្តី Karemera) កថាខណ្ឌ ១១។

[៦១] *សូមមើល ឧទាហរណ៍* សាលដីកាលើរឿងក្តី Zigiranyirazo កថាខណ្ឌ១៤។ សាលដីកាលើរឿងក្តី Karemera កថាខណ្ឌ ១១។

[៦២] *កំណត់សម្គាល់ពិសេស៖* អសមត្ថភាពផ្នែកផ្លូវកាយ ដោយសារជម្ងឺមិនអាចចាត់ទុកថាជាការបោះបង់សិទ្ធិឡើយ ដូចក្នុងរឿងក្តី Nzirorera ដែលទាមទារដោយជនជាប់ចោទ។ សូមមើលសាលដីកាលើរឿងក្តី Karemera កថាខណ្ឌ២ និង ១៥។

[៦៣] *សូមមើល* សាលដីកាលើរឿងក្តី Karemera កថាខណ្ឌ១៥។ សាលដីកាលើរឿងក្តី Zigiranyirazo កថាខណ្ឌ ២០។

[៦៤] វិធាន៨១(៤)។

[៦៥] វិធាន៨១(៤)។

[៦៦] វិធាន៨១(៥)។ *កំណត់សម្គាល់ពិសេស៖* នៅក្នុងករណីបែបនេះ - នៅពេលដែលជនជាប់ចោទយល់ព្រមមិនបង្ហាញខ្លួន "គាត់ក៏អាចស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីតាមមធ្យោបាយសោតទស្សន៍បានដែរ"។ *ដូចដើងទំព័រខាងលើ*។

00641455



១៩. ប្រការដែលគួរឱ្យកត់សម្គាល់នោះគឺថា នៅក្នុងសវនាការរួមមួយ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR បានសម្រេចថា សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយមានវត្តមានរបស់ជនជាប់ចោទយកទៅអនុវត្តបានដូចគ្នានឹងការបង្ហាញសក្ខីកម្ម ដែលពាក់ព័ន្ធនឹងអំពើដែលត្រូវបានចោទប្រកាន់ និងការប្រព្រឹត្តរបស់សហជនជាប់ចោទតែប៉ុណ្ណោះ[៦៧]។ និយាយម្យ៉ាងទៀតបានថា នៅក្នុងសវនាការរួមគ្នា ជនជាប់ចោទមានសិទ្ធិមានវត្តមាន*ក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល*។

## V. ឧន្សីករណ៍

### ក. សំណើសុំអាចទទួលយកបាន

២០. អង្គជំនុំជម្រះបានទទួលសំណុំរឿងនេះចាប់តាំងពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១។ ដោយសារវិធាន ៣២ អនុញ្ញាតយ៉ាងច្បាស់លាស់ឱ្យភាគីនានាក្នុងកិច្ចដំណើរការនីតិវិធី លើកសំណើដើម្បីសុំតែងតាំងអ្នកជំនាញដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីសម្រេចថាតើ "ជនជាប់ចោទមានសម្បទាទាំងផ្លូវកាយ និងស្មារតីចូលរួមក្នុងការជំនុំជម្រះក្តីដែរឬយ៉ាងណានោះ" នោះសំណើសុំជាបន្ទាន់នេះអាចទទួលយកបាន។

### ខ. ដោយសារសម្បទារបស់លោក នួន ជា ក្នុងការចូលរួមសវនាការមានភាពមិនច្បាស់លាស់ជាសត្យានុម័ត នោះអង្គជំនុំជម្រះសាលាដំបូងគួរចេញសេចក្តីសម្រេចឱ្យមានការវាយតម្លៃពីអ្នកជំនាញ

២១. លោក **នួន ជា** មិនទាន់បានទទួលការវាយតម្លៃទៅលើសម្បទាឱ្យបានទូលំទូលាយនៅឡើយទេ។ ក្រៅពីការពិនិត្យសុខភាពជាទៀងទាត់ដោយគ្រូពេទ្យបេះដូង និងបុគ្គលិកពេទ្យដែលត្រូវបានតែងតាំងឱ្យបំពេញការងារនៅក្នុងមន្ទីរឃុំឃាំង អវតក មិនមានការពិនិត្យសុខភាពដូចដែលបានចែងនៅក្នុងវិធាន៣២ និងយុត្តិសាស្ត្រពាក់ព័ន្ធទេ។ ដូចបានសម្គាល់មកខាងលើរួចមកហើយ កំណត់ហេតុអំពីអង្គហេតុត្រូវមានភាពពេញលេញ ដើម្បីបង្ហាញពីសមត្ថភាពរបស់ជនជាប់ចោទក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីឱ្យមានប្រសិទ្ធភាព អាចទទួលរងការប៉ះពាល់យ៉ាងខ្លាំង[៦៨]។ នៅគ្រប់កាលៈទេសៈទាំងអស់ អ្នកជំនាញពីមុនបានសន្និដ្ឋានពីបញ្ហាសម្បទារបស់ លោក **នួន ជា** ក្នុងការចូលរួមសវនាការថា "ត្រូវការធ្វើការវាយតម្លៃជាថ្មី នៅពេលដែលកិច្ចដំណើរការនីតិវិធីជំនុំ

---

[៦៧] សាលដីកាលើរឿងក្តី Karemera កថាខណ្ឌ១៥។

[៦៨] *សូមមើល* កថាណ្ឌ ៧(ក) ដល់ (ង) *ខាងលើ*។

ជម្រះត្រូវបានធ្វើឡើង”[៦៩]។

២២. ប្រការដែលត្រូវសង្កត់ធ្ងន់គឺថា ក្រុមមេធាវីការពារក្ដីមិនមានបំណងបង្ហាញថា លោក **នួន ជា** មិនមានសម្បទាចូលរួមក្នុងការជំនុំជម្រះក្ដី ឬថា កិច្ចដំណើរការនីតិវិធីគួរតែបញ្ឈប់ដោយផ្អែកលើមូលដ្ឋាននេះទេ។ ផ្ទុយទៅវិញ សំណើសុំជាបន្ទាន់នេះតម្រូវ នៅក្នុងដំណាក់នៃកិច្ចដំណើរការនីតិវិធីនេះតែម្ដង ដែលត្រូវដំណើរការក្នុងការតែងតាំងអ្នកជំនាញដែលមានគុណសម្បត្តិគ្រប់គ្រាន់ ដើម្បីវាយតម្លៃពីសមត្ថភាពរបស់ជនជាប់ចោទ។ ភាពខុសគ្នានេះជាចំណុចមួយសំខាន់។ នៅក្នុងរឿងក្ដី *Strugar* មេធាវីការពារក្ដីអាចចូលរួមដោយផ្ទាល់ក្នុងការតែងតាំងអ្នកជំនាញផ្នែកសម្បទាដែលមានគុណសម្បត្តិគ្រប់គ្រាន់ និងជាចុងក្រោយ បានដាក់របាយការណ៍របស់ខ្លួនដើម្បីគាំទ្រដល់សំណើសុំបញ្ឈប់កិច្ចដំណើរការនីតិវិធី។ ចំណុចនេះផ្ទុយពីនីតិវិធីដែលបានអនុវត្តនៅ អវតក ដែលមេធាវីការពារក្ដីត្រូវពឹងផ្អែកទាំងស្រុងទៅលើចៅក្រម ដើម្បីធ្វើការតែងតាំងអ្នកជំនាញជាចាំបាច់។ អាស្រ័យហេតុនេះ ទើបលក្ខខណ្ឌនៃសំណើសុំដែលមានលក្ខណៈបន្ទាន់បែបនេះគួរតែទាបជាងលក្ខខណ្ឌដែលបានរៀបរាប់នៅក្នុងរឿងក្ដី *Strugar* និងត្រូវបានសម្រេចទទួលយកដោយ អបជ។

២៣. នៅក្នុងករណីលោក **នួន ជា** - ដែលជាចុងចោទមានវ័យចាស់ និងទ្រុឌទ្រោម កំពុងប្រឈមមុខនឹងសវនាការនៅក្នុងនីតិវិធីប្រព័ន្ធច្បាប់ស៊ីវិលដែលដឹកនាំដោយចៅក្រម (ខុសពីប្រព័ន្ធដែលដឹកនាំដោយភាគី) នោះសច្ចធារណ៍ស្ដីពីសម្បទាណាមួយ (ទៅតាមវិសាលភាពដែលមាននៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ) ត្រូវបានច្រានចោលដោយភស្ដុតាងដែលមានរៀបរាប់ខាងលើ ដែលត្រូវយកមកពិចារណាទៅលើសមត្ថភាពរបស់ជនជាប់ចោទ ក្នុងការជួយមេធាវីការពារក្ដីរបស់ខ្លួនយ៉ាងមានប្រសិទ្ធភាព និងចូលរួមក្នុងកិច្ចដំណើរការនីតិវិធី។ “ភាពពេញលេញ” នៃសំអាងហេតុនេះគួរត្រូវបានវាយតម្លៃ ទាក់ទិននឹងតួនាទីជាមូលដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការធានាពីភាពយុត្តិធម៌នៃសវនាការ។ ក្នុងន័យនេះ បន្ទុកបែបនេះមិនគួរស្ថិតក្នុងកណ្ដាប់ដៃមេធាវីការពារក្ដីទេ តែផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចដោយខ្លួនឯង ដោយសារវាជាបញ្ហាគន្លឹះ ដែលថា ជនជាប់ចោទទាំងឡាយណាដែលត្រូវមានវត្តមាននៅក្នុងការជម្រះក្ដី ត្រូវតែមានសម្បទាដើម្បីចូលរួមក្នុងសវនាការ[៧០]។

---

[៦៩] របាយការណ៍អ្នកជំនាញមុន ទំព័រ៦។

[៧០] *សូមមើល* កថាខណ្ឌ ១៥ *ខាងលើ*។

២៤. សន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងគួរស្វែងរកការអនុវត្តលក្ខខណ្ឌមួយដែលខ្ពស់ជាងភាពគ្រប់គ្រាន់ (ដូចដែល អបជ ធ្លាប់បានធ្វើ) ដែលលក្ខណៈវិនិច្ឆ័យបែបនេះពិតជាស្របទៅនឹងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ។ ទោះបី អបជ មិនមានសំអាងហេតុពេញលេញដើម្បីធ្វើយុត្តិកម្មពីការតែងតាំងអ្នកជំនាញតាមវិធាន៣២ ស្ដីពីអ្នកជំនាញ នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៨[៧១] ក៏ដោយ ក៏ការប៉ុនប៉ងចុងក្រោយរបស់ កសចស ដើម្បីវាយតម្លៃពីសម្បទាបានបង្ហាញយ៉ាងច្បាស់ថាមានសំអាងហេតុគ្រប់គ្រាន់ដើម្បីបំពេញការងារនេះត្រឹមខែកញ្ញា ឆ្នាំ២០០៩[៧២] ប៉ុណ្ណោះ។ ការពិតប្រសិនបើសំអាងហេតុបែបនេះមានតាំងពីពេលនោះមក វាក៏ទំនងជានៅមានបន្តទៀត *(a fortiori)* រយៈពេលជាងមួយឆ្នាំទៀត។ ជាងនេះទៅទៀត ក្នុងការប៉ុនប៉ងធ្វើការវាយតម្លៃពីអ្នកជំនាញពីមុនបានសង្កត់ធ្ងន់ពីតម្រូវការឱ្យមាន*ការវាយតម្លៃជាថ្មី* ទៅលើការសន្និដ្ឋាននានាដែលអាចនឹងកើតមាននៅពេលកិច្ចដំណើរការនីតិវិធីសវនាការត្រូវបានធ្វើឡើង[៧៣]។ នាពេលនេះ ដោយសារការមកដល់របថផ្លូវបែបនេះហើយ ទើបវាជាការមិនត្រឹមត្រូវនោះទេ ចំពោះការមិនអនុវត្តតាមដំបូន្មានរបស់អ្នកជំនាញលើកមុនទៅលើចំណុចនេះ។

## គ. អង្គជំនុំជម្រះសាលាដំបូងគួរផ្ដល់ការណែនាំដល់អ្នកជំនាញលើកមុន ឱ្យរៀបចំបំពេញលក្ខណៈវិនិច្ឆ័យទៅលើសម្បទាដែលឆ្លុះបញ្ចាំងយ៉ាងពេញលេញពីភាពស្មុគស្មាញនៃកិច្ចដំណើរការនីតិវិធី និងភាពជាក់ស្ដែងនៃស្ថានភាពរបស់ជនជាប់ចោទ

២៥. ភាពស្មុគស្មាញ និងភាពធ្ងន់ធ្ងរនៃបទចោទ និងការប្ដឹងជំទាស់ ដែលលោក **នួន ជា** កំពុងប្រឈមមុខនៅ អវតក ទំនងមានការរំពឹងថា តម្រូវឱ្យគាត់មានសមត្ថភាពច្រើនជាងមុនក្នុងនាមជាចុងចោទ នៅក្នុងរឿងក្ដីពិសេសមួយនេះ។ ដូច្នេះ អ្វីដែលត្រូវការនៅដំណាក់កាលដំបូងនៃការពិចារណាទៅលើសម្បទាណាមួយនោះ គឺការកំណត់អត្តសញ្ញាណនៃសមត្ថភាពជាក់លាក់ ដែលជនជាប់ចោទត្រូវការដើម្បីបំពេញមុខងាររបស់ខ្លួនឱ្យបានពេញលេញនៅក្នុងប្រព័ន្ធ អវតក ហើយប្រសិន

---

៧១ *សូមមើល* កថាខណ្ឌ ៤ *ខាងលើ*។

៧២ *សូមមើល* កថាខណ្ឌ ៥ *ខាងលើ*។

៧៣ *ដូចដែលទំព័រខាងលើ*។ កំណត់សម្គាល់៖ យោងតាមយោបល់របស់អ្នកជំនាញមុន ការពិនិត្យឡើងវិញបន្ថែមទៀតបែបនេះ គឺជាការចាំបាច់ ដោយមិនគិតពីលទ្ធផលនៃពិនិត្យមុនៗនោះទេ ប្រសិនបើមានរបាយការណ៍ពិនិត្យសម្បទាបានបំពេញសព្វគ្រប់ហើយនោះ។

00641458



បើគាត់អវត្តមាន នោះអាចនឹងលេចចេញជាលទ្ធផលថា សវនាការនេះមានភាពអយុត្តិធម៌។ ដោយសារថា ការសម្រេចពីសម្បទារបស់លោក **នួន ជា** ក្នុងការចូលរួមក្នុងការជម្រះក្តីនឹងទទួលរងឥទ្ធិពលគួរឲ្យកត់សម្គាល់ដោយសារភស្តុតាងរបស់អ្នកជំនាញនោះ នោះវាជាប្រការសំខាន់ដែលត្រូវកាត់បន្ថយនូវកត្តាអត្តនោម័ត និងការធ្វើអ្វីតាមអំពើចិត្ត នៅក្នុងដំណើរការវាយតម្លៃនេះ (តាមតែអាចធ្វើទៅបាន) ដោយផ្តល់នូវសេចក្តីណែនាំច្បាស់លាស់ដល់អ្នកជំនាញដែលបានស្នើសុំ ដើម្បីបញ្ជាក់ឲ្យច្បាស់លាស់ថាអ្វីទៅដែលជាសម្បទាស្ថិតក្រោមកាលៈទេសៈពិសេសបែបនេះ។

២៦. ក្នុងការរៀបចំសេចក្តីណែនាំ មេធាវីការពារក្តីជំរុញឲ្យអង្គជំនុំជម្រះសាលាដំបូងកែលំអលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Strugar* ទាក់ទិននឹងពេលវេលា និងការរៀបចំកិច្ចដំណើរការនីតិវិធី។ ដូចបានរៀបរាប់រួចមកហើយថា នេះជាភស្តុតាងដែលបញ្ជាក់ខ្លួនឯងថា សម្បទារបស់ជនជាប់ចោទក្នុងការចូលរួមក្នុងការជម្រះក្តី ពឹងផ្អែកទៅលើប្រភេទនៃសវនាការដែលរំពឹងទុកនោះ ក្នុងករណីនេះគឺជារយៈពេលមួយដ៏វែង និងមានភាពស្មុគស្មាញយ៉ាងខ្លាំង។ អាស្រ័យហេតុនេះ លក្ខណៈវិនិច្ឆ័យត្រូវធ្វើទៅតាមបរិបទឲ្យបានពេញលេញ និងរៀបចំឡើងដើម្បីបញ្ចៀសនូវការសម្រេចចិត្តនានាដោយផ្អែកលើភាពខុសគ្នាជាធម្មតានៃសម្បទាពេញលេញ/មិនពេញលេញ វិធីសាស្ត្រដោយឡែកបែបនេះនឹងមិនបានបញ្ចូលទាំងភាពស្មុគស្មាញនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ និងភាពជាក់ស្តែងនៃស្ថានភាពសុខភាពផ្នែករាងកាយ និងផ្លូវចិត្តរបស់លោក **នួន ជា** នោះទេ។

២៧. ដោយផ្អែកលើមូលដ្ឋានបែបនេះ និងក្នុងគោលបំណងធានាការការពារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ រួមទាំងកិច្ចដំណើរការនីតិវិធីសវនាការឲ្យមានប្រសិទ្ធភាពផងនោះ សេចក្តីណែនាំចំពោះអ្នកជំនាញដែលបានស្នើសុំមិនត្រឹមតែបញ្ជាក់ពីសញ្ញាណនៃពាក្យថា “សម្បទា” ប៉ុណ្ណោះទេ តែក៏ត្រូវយល់ដឹងពីអត្ថន័យនៃពាក្យថា “ការជម្រះក្តី” ផងដែរ ដោយសារពាក្យនេះត្រូវបានយល់ដឹងជាពិសេសនៅ អវតក។ ដើម្បីអនុវត្តបេសកកម្មការងាររបស់ខ្លួនប្រកបដោយជោគជ័យបាន អ្នកជំនាញដែលបានស្នើសុំនោះត្រូវមានកម្រិតយល់ដឹងជាអប្បរមាទាំងទំហំ និងចំណុចដែលគួរឲ្យកត់សម្គាល់ពីដំណើរការដែលនឹងត្រូវបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ចំណុចសំខាន់នៅក្នុងទិដ្ឋភាពនេះគឺថា គួរទទួលយកទស្សនៈរបស់អ្នកជំនាញដែលបានស្នើសុំនោះចំពោះរយៈពេលសមស្របនៃសវនាការ ការតម្រូវឲ្យមានការសម្រាកយកកម្លាំងក្នុងចន្លោះពេលខ្លីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ដែលជាវិធានការប្រឆាំងទល់នឹងកម្រិតទូទៅនៃសម្បទារបស់ជនជាប់ចោទ។

២៨. ក្រៅពីការរំពឹងថា អ្នកជំនាញដែលបានស្នើសុំនឹងធ្វើការវិភាគយ៉ាងល្អិតល្អន់ចំពោះយុត្តិសាស្ត្រ

របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ[៧៤] អង្គជំនុំជម្រះសាលាដំបូងគួរតែរៀបចំនូវបទដ្ឋានដែលយកមកអនុវត្តឲ្យបានច្បាស់លាស់ជាមុន និងបង្ហាញវិធីសាស្ត្រដែលមានប្រសិទ្ធភាពបំផុត។ សេចក្តីណែនាំនោះមិនត្រឹមតែរៀបរាប់ពីសមត្ថភាពពាក់ព័ន្ធទាំងអស់នោះទេ តែអង្គជំនុំជម្រះសាលាដំបូងគួរតែណែនាំដល់អ្នកជំនាញដែលបានស្នើសុំផងដែរ អំពីរបៀបសម្រេចថាតើជនជាប់ចោទមានសមត្ថភាពទាំងនេះដែរឬអត់។ វិធីសាស្ត្របែបនេះ គឺត្រឹមតែជាការផ្តល់ការបង្ហាញណែនាំដែលងាយយល់ និងដោយប្រុងប្រយ័ត្ន ប៉ុន្តែ មិនត្រូវមានការជ្រៀតជ្រែកចូលក្នុងកិច្ចការជំនាញរបស់អ្នកជំនាញដែលបានស្នើសុំនោះឡើយ ទោះជាតាមរូបភាពណាក៏ដោយ។

២៩. សង្ខេបមក ដោយការប្រើប្រាស់លក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Strugar* ជាចំនុចចាប់ផ្តើម[៧៥] សេចក្តីណែនាំចំពោះអ្នកជំនាញដែលបានស្នើសុំ គួរតែពន្យល់ឲ្យបានពិស្តារ និងច្បាស់លាស់ ដែលសម្រេចយកពីវិធីសាស្ត្រនានាដែលបានពិភាក្សាខាងលើ[៧៦] ទាក់ទិននឹងបញ្ហានានាដែលបានរៀបរាប់នៅក្នុងសំណើសុំនេះ។ វាជាប្រការសមស្របដែលថា មួយផ្នែក ដោយសារមានភាពខុសគ្នារវាងវិធានតាមផ្លូវច្បាប់ និងផ្នែកវេជ្ជសាស្ត្រ នោះការយល់ច្រឡំពីចរិតលក្ខណៈ និងវិសាលភាពនៃអាណត្តិការងាររបស់អ្នកជំនាញដែលបានស្នើសុំ អាចនឹងកើតមានឡើងយ៉ាងងាយបំផុត។ ឧទាហរណ៍មួយនៃការយល់ច្រឡំបែបនេះអាចរកឃើញបាននៅក្នុងរឿងក្តី *Strugar* នៅពេលដែលអ្នកជំនាញម្នាក់ក្នុងចំណោមអ្នកជំនាញទាំងនោះពឹងផ្អែកការវាយតម្លៃរបស់ខ្លួនពីសម្បទានៃសមត្ថភាពរបស់ជនជាប់ចោទ ក្នុងការយល់ដឹង*ពេញលេញ*ពីកិច្ចដំណើរការនីតិវិធី[៧៧]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ចំណុចនេះហួសឆ្ងាយពីបទដ្ឋាននៃការយល់ដឹង[៧៨]។ ដូចគ្នានេះដែរ ក្នុងរឿងក្តី *Nahak* អ្នកជំនាញម្នាក់ក្នុងចំណោមអ្នកជំនាញទាំងនោះ ក៏បានទទួលរងការរិះគន់

---

[៧៤] *សូមមើល* ឯកសារ B-35 "ដីកាចាត់តាំងអ្នកជំនាញ" ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩, ERN 00379010–00379013, ទំព័រ២ (ERN 00379011) ។

[៧៥] សមត្ថភាពដែលបានកំណត់ រួមមាន សមត្ថភាពក្នុងការសារភាព ការយល់ដឹងពីលក្ខណៈនៃបទចោទប្រកាន់ទោស ការយល់ដឹងពីកិច្ចដំណើរការនីតិវិធី ការយល់ដឹងពីព័ត៌មានពិស្តារនៃភស្តុតាង ការណែនាំដល់មេធាវីការពារក្តី ការយល់ដឹងពីវិបាកនៃកិច្ចដំណើរការនីតិវិធី និងការធ្វើសក្ខីកម្ម។ រឿងក្តី *Strugar* កថាខណ្ឌ៣៦។

[៧៦] *សូមមើល* កថាខណ្ឌ ១២ ដល់ ១៤ ខាងលើ។

[៧៧] *សូមមើល រឿងក្តី* *Strugar* កថាខណ្ឌ៤៨។

ថា មិនបានអនុវត្តបទដ្ឋានស្តីពីសមត្ថភាពដែលបានប្រកាសដោយតុលាការនោះទេ[79]។ ដើម្បីចៀសវាងនូវបញ្ហាស្រដៀងគ្នានេះ សេចក្តីណែនាំចំពោះអ្នកជំនាញដែលបានស្នើសុំ និងវិសាលភាពនៃបេសកកម្មការងាររបស់ខ្លួនត្រូវតែមានលក្ខណៈច្បាស់លាស់[80]។

## ឃ. របាយការណ៍របស់អ្នកជំនាញដែលបានស្នើសុំគួរយកមកប្រើ*យ៉ាងតឹងរ៉ឹង* សម្រាប់គោលបំណងសម្រេចពីសម្បទារបស់លោក នួន ជា ដើម្បីចូលរួមក្នុងការជំនុំជម្រះក្តី

៣០. មេធាវីការពារក្តីទទួលស្គាល់ថា ជំហររបស់ខ្លួនទាក់ទិននឹងការពិនិត្យសម្បទាដែលត្រូវបង្គាប់ដោយ កសចស[81] អាចធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងផ្អាកដំណើរការសិន ដើម្បីពិចារណាថាតើមេធាវីការពារក្តីនឹងសម្រេចយកឥរិយាបថស្រដៀងគ្នានេះ ចំពោះដីកាសម្រេចអំពីការពិនិត្យសម្បទានាពេលអនាគត ឬយ៉ាងណានោះ។ ការសហការជាមួយដីកាសម្រេចពីមុនមិនអាចធ្វើទៅបានទេ ដោយសារលក្ខណៈមិនច្បាស់លាស់ និងអន្តរាយដែលបណ្តាលមកពីការប្រើប្រាស់លទ្ធផលនៃការពិនិត្យសម្បទាមិនត្រឹមត្រូវ[82]។ ដោយការសន្មតថា កម្មវត្ថុ និងគោលបំណងនៃដីកាសម្រេចដែលចេញដោយអង្គជំនុំជម្រះសាលាដំបូង គឺពាក់ព័ន្ធផ្តាច់មុខតែនឹងការសម្រេចពីកម្រិតនៃសម្បទារបស់លោក **នួន ជា** ដើម្បីចូលរួមក្នុងការជំនុំជម្រះក្តី នោះមេធាវីការពារក្តីនឹងផ្តល់យោបល់ឱ្យគាត់

---

[78] *សូមមើល រឿងក្តី Strugar* កថាខណ្ឌ៤៨។

[79] *សូមមើល រឿងក្តី Nahak* កថាខណ្ឌ១២៤-១៣៤។

[80] *កំណត់សម្គាល់ពិសេស៖* នៅក្នុងដីកាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ កសចស ខកខានមិនបានបញ្ជាក់ឱ្យបានច្បាស់តាមកម្រិតពិស្តារ និងត្រឹមត្រូវ ហេតុនេះវាបណ្តាលឱ្យកើនឡើងនូវមហន្តរាយដោយសារការវាយតម្លៃមិនគ្រប់គ្រាន់ និងមិនត្រឹមត្រូវ។ នៅក្នុងចំណុចទីបីនៃបេសកកម្មការងារ កសចស ខកខានមិនបានកំណត់លក្ខណៈវិនិច្ឆ័យពីសម្បទាឱ្យបានច្បាស់ និងមិនបានពន្យល់ពីរបៀបដែលអ្នកជំនាញគួរអនុវត្តតាមលក្ខណៈវិនិច្ឆ័យទាំងនោះ។ ផ្ទុយទៅវិញ ដោយគ្រាន់តែនិយាយយោងយ៉ាងទូលំទូលាយទៅក្នុងរឿងក្តី *Strugar* បណ្តោយឱ្យអ្នកជំនាញលើកមុនបង្កើតនូវបទដ្ឋានត្រឹមត្រូវ។ ដោយសារមានគ្រោះថ្នាក់ដូចបានពិភាក្សាមកខាងលើបែបនេះហើយ ទើបវាជាការសំខាន់ (និងកាន់តែមានប្រសិទ្ធិភាព) ដែល កសចស ត្រូវបញ្ជាក់ឱ្យបានពិស្តារនូវបទដ្ឋានដែលត្រឹមត្រូវ។ គេអាចរកឃើញនូវការណែនាំមិនច្បាស់លាស់នេះ នៅក្នុងរបាយការណ៍អ្នកជំនាញលើកមុន ដែលបានគូសបញ្ជាក់ថា ការយល់ដឹងរបស់ពួកគេចំពោះបទដ្ឋានដែលអាចអនុវត្តបាន មិនលើសពីសញ្ញាណទូលំទូលាយនៃពាក្យថា "ការចូលរួមយ៉ាងពេញលេញទេ"។ ទោះបីវាអាចនឹងមានន័យសំដៅដល់បទដ្ឋាននៃសម្បទាក៏ដោយ ក៏វាជាការមើលរំលងនូវភាពលាយឡំគ្នានៃភាពជាក់ស្តែងដែរ។

[81] *សូមមើល* កថាខណ្ឌ ៥ ខាងលើ។

[82] *ដូចជើងទំព័រខាងលើ*។

សហការឲ្យបានពេញលេញជាមួយអ្នកជំនាញដែលបានស្នើសុំនេះ។

៣១. ដើម្បីការពារបុព្វសិទ្ធិរបស់លោក **នួន ជា** ប្រឆាំងនឹងការធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង អង្គជំនុំជម្រះសាលាដំបូងគួរសម្រេចថា របាយការណ៍ដែលបានដាក់ដោយអ្នកជំនាញដែលបានស្នើសុំ នឹងត្រូវយកទៅប្រើប្រាស់តែដើម្បីគោលបំណងជាក់លាក់ ដោយមានការស្នើសុំតែប៉ុណ្ណោះ ពោលគឺដើម្បីវាយតម្លៃពីសម្បទារបស់ជនជាប់ចោទដើម្បីចូលរួមសវនាការ ដូចមានចែងក្នុងវិធាន៣២។ កង្វល់របស់មេធាវីការពារក្តីបានកើតឡើងពីអន្តរកម្មសំខាន់រវាងប្រយោគចុងក្រោយនៃវិធាននេះ ដែលបានចែងថា៖ របាយការណ៍អ្នកជំនាញស្តីពីសម្បទា "ត្រូវដាក់ចូលក្នុងសំណុំរឿង" ហើយប្រយោគទីមួយនៃវិធាន៨៧(៣) ដែលចែងថា៖ អង្គជំនុំជម្រះសាលាដំបូង "ធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង"។ នៅពេលអានវិធានទាំងពីរនេះបញ្ចូលគ្នា វិធានទាំងនេះបានបង្កើតជាសំណួរមួយថាតើ របាយការណ៍ដែលមានចែងក្នុងវិធាន៣២ នៅក្នុងសំណុំរឿង អាចយកមកប្រើប្រាស់ជា "ភស្តុតាង" ដើម្បីសម្រេចពីពិរុទ្ធភាពរបស់លោក **នួន ជា** ចំពោះឧក្រិដ្ឋកម្មដែលគាត់ទទួលរងការចោទប្រកាន់ដែរឬអត់នោះ។ មេធាវីការពារក្តីសូមស្នើថា ចម្លើយទៅនឹងសំណួរនេះត្រូវតែជាចម្លើយអវិជ្ជមាន។ ក្នុងន័យនេះ អង្គជំនុំជម្រះសាលាដំបូងគួរណែនាំឲ្យបានច្បាស់ដល់អ្នកជំនាញដែលបានស្នើសុំ កុំឲ្យពិភាក្សាជាមួយលោក នួន ជា អំពីបទចោទប្រកាន់ណាមួយដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

៣២. យោងតាមគោលបំណងពិសេសនៃវិធាន៣២ លទ្ធផលនៃការពិនិត្យដែលបានប្រព្រឹត្តទៅតាមពាក្យពេចន៍របស់វា គួរតែយកទៅប្រើប្រាស់សម្រាប់តែគោលបំណង*ផ្តាច់មុខ* ក្នុងការសម្រេចពីសម្បទារបស់ជនជាប់ចោទដើម្បីចូលរួមក្នុងការជំនុំជម្រះក្តីតែប៉ុណ្ណោះ លើកលែងតែលោក **នួន ជា** ខ្លួនឯងយល់ស្របឲ្យយកទៅប្រើប្រាស់សម្រាប់គោលបំណងផ្សេងទៀត។ លើកលែងតែមិនមានហានិភ័យណាមួយដែលកើតចេញពីផលវិបាកផ្ទុយគ្នានេះ នោះរំពឹងថា ជនជាប់ចោទនឹងសហការយ៉ាងពេញលេញ និងមានប្រសិទ្ធភាពក្នុងការវាយតម្លៃអំពីសម្បទានេះ។

### ង. លោក នួន ជា មិនលះបង់សិទ្ធិមានវត្តមាននៅទូទាំងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី

៣៣. ដោយសារជាបញ្ហាគោលការណ៍មូលដ្ឋាន លោក **នួន ជា** មិនបានលះបង់សិទ្ធិក្នុងការបង្ហាញខ្លួននៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីនៃការជម្រះក្តីនាពេលខាងមុខនេះទេ រួមទាំងផ្នែកខ្លះនៃសវនាការលើអង្គសេចក្តី ដែលទំនងជាទាក់ទិនតែនឹងអំពើនានាដែលត្រូវបានចោទប្រកាន់

00641462



និងការប្រព្រឹត្តរបស់សហជនជាប់ចោទរបស់គាត់។

## VI. សន្និដ្ឋាន

៣៤. ចំពោះសំអាងហេតុដូចបានលើកឡើងខាងលើ មេធាវីការពារក្ដីស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង៖

ក. ចាត់តាំងអ្នកជំនាញម្នាក់/ច្រើននាក់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីសម្រេចថាតើលោក **នួន ជា** មានសម្បទាទាំងផ្នែករាងកាយ និងផ្លូវចិត្ត ដើម្បីចូលរួមក្នុងការជំនុំជម្រះក្ដីដែរឬយ៉ាងណានោះ។

ខ. ណែនាំដល់អ្នកជំនាញរូបនោះ/ទាំងនោះ ទៅតាមជំហាននានាដែលបានលើកជាទឡ្ហីករណ៍ និងអះអាងនៅក្នុងសំណើសុំនេះ។

គ. បង្គាប់ថា រាល់របាយការណ៍ដែលបានរៀបចំដោយអ្នកជំនាញរូបនោះ/ទាំងនោះ នឹងត្រូវយកទៅប្រើប្រាស់ដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីសម្រេចអំពីកាយសម្បទារបស់លោក **នួន ជា** ដើម្បីចូលរួមក្នុងការជំនុំជម្រះក្ដីតែមួយប៉ុណ្ណោះ លើកលែងតែជនជាប់ចោទខ្លួនឯងយល់ព្រមឲ្យយកទៅប្រើប្រាស់ក្នុងករណីផ្សេងទៀត។

ដោយសារលក្ខណៈបន្ទាន់នៃសំណើសុំនេះ មេធាវីការពារក្ដីស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសំណើសុំនេះជាបញ្ហាបន្ទាន់បង្ខំ។

សហមេធាវីការពារក្ដីលោក **នួន ជា**

**សុន អរុណ**

Michiel PESTMAN **និង** Victor KOPPE